# II. ទីស្ដីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៤

**អនុក្រឹត្យ លេខ ០៣ អនក្រ**

**ស្ដីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រី រាជការ**

**និយោជិត កម្មករ ប្រចាំឆ្នាំ ១៩៩៤**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើររបស់សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៤

**សំរេច**

**មាត្រា ១ :** អនុញ្ញាតអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បានឈប់សំរាកការងារ ប្រចាំឆ្នាំ ១៩៩៤ តាមប្រតិទិនដូចខាងក្រោម ÷

| | |
|---|---|
| ១- ថ្ងៃទី ០១ ខែ មករា | : ទិវាចូលឆ្នាំសកល ១ ថ្ងៃ |
| ២- ថ្ងៃទី ០៨ ខែ មិនា | : ទិវានារីអន្តរជាតិ ១ ថ្ងៃ |
| ៣- ថ្ងៃទី ១៤- ១៥- ១៦ ខែ មេសា | : បុណ្យចូលឆ្នាំខ្មែរ ៣ ថ្ងៃ |
| ៤- ថ្ងៃទី ០១ ខែ ឧសភា | : ទិវាពលកម្មអន្តរជាតិ ១ ថ្ងៃ |
| ៥- ថ្ងៃទី ២៤ ខែ ឧសភា | : បុណ្យវិសាខបូជា ១ ថ្ងៃ |

៦- ថ្ងៃទី ២៥ -២៦- ២៧ ខែ ឧសភា : បុណ្យច្រត់ព្រះនង្គ័ល ៣ ថ្ងៃ
៧- ថ្ងៃទី ០១ ខែ មិថុនា : ទិវាកុមារ អន្តរជាតិ ១ ថ្ងៃ
៨- ថ្ងៃទី ២៤ ខែ កញ្ញា : ទិវាប្រកាសប្រើរដ្ឋធម្មនុញ្ញ ១ ថ្ងៃ
៩- ថ្ងៃទី ០៤- ០៥- ៦ ខែ តុលា : បុណ្យភ្ជុំបិណ្ឌ ៣ ថ្ងៃ
១០- ថ្ងៃទី ២៣ ខែ តុលា : ទិវាសន្ធិសញ្ញាសន្តិភាពកម្ពុជា នៅប៉ារីស ១ ថ្ងៃ
១១- ថ្ងៃទី ៣០- ៣១ ខែ តុលា និងថ្ងៃទី ០១ ខែវិច្ឆិកា : បុណ្យចំរើនព្រះជន្ម ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង បុណ្យតាំងតុ ៣ ថ្ងៃ ។
១២- ថ្ងៃទី ០៩ ខែវិច្ឆិកា : បុណ្យឯករាជ្យជាតិ ១ ថ្ងៃ
១៣- ថ្ងៃទី ១៧- ១៨- ១៩ ខែវិច្ឆិកា : បុណ្យអុំទូក អកអំបុក បណ្តែតប្រទីប សំពះព្រះខែ ៣ ថ្ងៃ
១៤- ថ្ងៃទី ១០ ខែ ធ្នូ : ទិវាសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ ១ ថ្ងៃ

មាត្រា ២ : ពេលវេលាឈប់សំរាកទាំងឡាយណា ដែលត្រូវចំថ្ងៃអាទិត្យ ត្រូវបានអនុញ្ញាតអោយឈប់សំរាក ១ ថ្ងៃបន្ថែម ។

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ នៃគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

**នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋ មន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា | ហត្ថលេខា និង ត្រា
**នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន**

* * *